P N K S

# NEWSLETTER



## How Mr Phoung Phalla went from a laborer to a model farmer

*Everything changed when Mr. Phoung Phalla joined the PNKS community-supported training program. Previously, he grew vegetables only for family consumption. However, new techniques drastically reduced his production time from 50 days to just 30 days.*

*In the past six months, he earned 460,000 riel (114USD) for the first time.*

*Once a contract laborer, Mr. Phoung Phalla now has the opportunity to be selected as a key farmer, allowing him to mentor and train others.*

## Co-Design workshop for Together Build Community Dignity (TBCD) project phase 2

Community participation is very important to us. PNKS organized a co-design workshop using data collected from the community to inform the planning for the next three years of the project. The project was designed with the community in mind, allowing them to voice their challenges and aspirations through collaborative assessment.

Community members had the opportunity to provide input and express the support they needed. Co-design ensures that the project addresses their real needs — a core value of PNKS.

One participant shared, "I'm happy because this is my first time joining a co-design workshop and being directly involved in planning the next three years alongside the donors and the organization."

Co-design exercise on power dynamics with community members in Ou Svay was an integral part of the new Phase 2 of the TBCD project. Through this exercise, the community began to understand aspects they had never recognized before: who holds the power, where that power originates, and which groups or individuals are the most vulnerable.



# COMMUNITY EXCHANGE TO STRENGTHEN SAVING GROUPS AND DEVELOPMENT

PNKS facilitated a community learning exchange between community people of Chey Saen in Preah Vihear and Chek village in Kampong Speu, a former target village of PNKS that was phased out in 2019. Chek village has successfully implemented a self-sustaining savings group until the present day. The community shared their strategies and success stories regarding its operation. Participants were impressed and expressed their gratitude for the opportunity to learn from Chek village community's experiences, with plans to implement similar strategies in their own communities.



Village center built by Saving group in Chek village (above)



## Active Citzenship training

SKYE youth (Skills, Knowledge, Youth, and Economic Empowerment) participated in an active citizenship training, where they gained hands-on experience in project planning, management, and implemen-tation

The training focused on strengthening their leadership and facilitation skills while equipping them with the knowledge and tools to lead community development initiatives. Through this process, youth were empowered to become agents of positive change in their communities.



## From Traditional to Resilient: A Farming Journey in Pakdevoat

Mr. Rot Hen, a farmer from Pakdevoat, went from traditional farming methods to practicing climate-resilient vegetable farming. After joining CIDG (Community Initiative Development Group) through PNKS, he gained access to skills training, including drip irrigation.

The drip irrigation system has made maintenance easier, used less water, and reduced weeds, resulting in healthier vegetable growth.

Mr. Rot Hen has noticed significant progress, not only in his own life but also within his community. His village now has WASH facilities, sanitary latrines, and regular clean-up days, all contributing to improved community health.

He believes these changes are important for improving the lives of his family and other vulnerable groups.

P N K S

# សារព័ត៌មាន



## លោក ផង ផល្លាពី កម្មករស៊ីឈ្នួលទៅជាកសិករគំរូ

អ្វីៗបានផ្លាស់ប្ដូរទាំងស្រុង ក្រោយពីលោក ផង ផល្លា បានចូលរួមកម្មវិធីបណ្ដុះបណ្ដាលជាមួយសហគមន៍ដែលបានគាំទ្រ ដោយPNKS។ ពីមុន លោកផល្លា គ្រាន់តែដាំបន្លែសម្រាប់ហូបក្នុងគ្រួសារប៉ុណ្ណោះ។ តែចំណេះដឹងបច្ចេកទេសថ្មីៗបានកាត់បន្ថយពេលវេលាដាំដុះ ពី ៥០ថ្ងៃ ចុះមកត្រឹមតែ ៣០ថ្ងៃប៉ុណ្ណោះ។

ក្នុងរយៈពេលប្រាំមួយខែចុងក្រោយនេះ ផល្លាបានចំណូលជាលើកដំបូងចំនួន ៤៦០,០០០ រៀល។

ពីជាកម្មករ មកទល់ពេលនេះ លោក ភួង ផល្លា កំពុងត្រូវបានជ្រើសរើសជាកសិករគំរូ ដែលអាចណែនាំ និង បណ្ដុះបណ្ដាលអ្នកដទៃបានផងដែរ។

## សិក្ខាសាលាស្ដីពីការប្រមូលព័ត៌មានពីសហគមន៍សម្រាប់រៀបចំផែនការគម្រោងបីឆ្នាំបន្ទាប់របស់គម្រោងTBCD

ការចូលរួមរបស់សហគមន៍ មានសារៈសំខាន់ណាស់ សម្រាប់យើង។ PNKS បានរៀបចំសិក្ខាសាលាកសាងផែនការ ដែលមានការចូលរួមពីសហគមន៍ (Co-design) ប្រើទិន្នន័យដែលសហគមន៍ និង PNKS បានប្រមូលជាមួយគ្នា ដើម្បីកសាងផែនការមួយជាមួយគ្នាសម្រាប់ បីឆ្នាំបន្ទាប់។ គម្រោងនេះត្រូវបានកសាងឡើងដោយយកសហគមន៍មូលដ្ឋានអនុញ្ញាតឱ្យសហគមន៍បង្ហាញពីបញ្ហា និងក្ដីសង្ឃឹមរបស់ខ្លួនតាមរយៈការវាយតម្លៃរួម។

សមាជិកសហគមន៍មានឱកាសផ្ដល់យោបល់ និងបង្ហាញពីការគាំទ្រដែលពួកគេចង់បាន។ ការរួមរចនាគឺធានាថា គម្រោងនឹងឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដរបស់ពួកគេ ដែលជាឈ្មោះគុណតម្លៃស្នូលរបស់ PNKS។

អ្នកចូលរួមរូបមួយបានបញ្ចេញអារម្មណ៍ថា៖ «ខ្ញុំមានមោទនភាព ពីព្រោះនេះជាលើកដំបូងដែលខ្ញុំបានចូលរួមសិក្ខាសាលារួមរចនា ហើយបានចូលរួមផ្ទាល់ក្នុងការធ្វើផែនការបីឆ្នាំក្រោយជាមួយអ្នកឧបត្ថម្ភ និងអង្គការ»។

សកម្មភាពស្ដីពី ឥទ្ធិពលអំណាច (Power Dynamic) ជាមួយសហគមន៍នៅឃុំអូរស្វាយ គឺជាផ្នែកដ៏សំខាន់មួយ ក្នុងការកសាងផែនការ នៃដំណាក់កាលទី ២ នៃគម្រោង TBCD។ តាមរយៈសកម្មភាពនេះ សហគមន៍បានចាប់ផ្ដើមយល់ដឹងពីអ្វីដែលគេមិនធ្លាប់បានគិតពីមុនមកដូចជា អ្នកណាជាអ្នកកាន់អំណាច អំណាចនោះមានប្រភពមកពីណា តើក្រុមឬបុគ្គលណាខ្លះដែលងាយរងគ្រោះបំផុត។ ចំណេះដឹងនេះជាផ្នែកមួយដ៏សំខាន់ ក្នុងការគិតដល់អ្នកងាយរងគ្រោះ ក្នុងកំឡុងពេលកសាងផែនការគម្រោងបន្ទាប់។



# ទស្សនៈកិច្ចសិក្សាស្ដីពីការសន្សំប្រាក់ និង គ្រប់គ្រងដើម្បីការអភិវឌ្ឍន៍

PNKS បានសម្របសម្រួលទស្សនកិច្ចសិក្សាផ្លាស់ប្ដូរបទពិសោធន៍រវាងសហគមន៍ក្រុមគំនិតផ្ដួចផ្ដើមមកពីស្រុកជ័យសែន ខេត្តព្រះវិហារ និង សហគមន៍ភូមិចេក ខេត្តកំពង់ស្ពឺ ដែលជាភូមិគោលដៅចាស់របស់គម្រោងPNKS ដែលបានដកចេញនៅឆ្នាំ២០១៩។

ភូមិចេកបានអនុវត្តក្រុមសន្សំដោយខ្លួនឯង និង ចូលរួមអភិវឌ្ឍន៍ភូមិបានយ៉ាងជោគជ័យ។ សហគមន៍ភូមិចេក បានចែករំលែកបទពិសោធន៍យុទ្ធសាស្ត្រជោគជ័យនៃក្រុមសន្សំរបស់ខ្លួន។ អ្នកចូលរួមមានការចាប់អារម្មណ៍ និង សម្ដែងអំណរគុណចំពោះឱកាសក្នុងការរៀនពីបទពិសោធន៍របស់សហគមន៍ភូមិចេក ហើយមានផែនការនឹងអនុវត្តយុទ្ធសាស្ត្រស្រដៀងគ្នានេះ នៅក្នុងសហគមន៍របស់ខ្លួនផងដែរ។



សាលាបុណ្យដែលសាងសង់ឡើងដោយសហគមន៍ក្រុមសន្សំភូមិចេក



## ការបណ្ដុះបណ្ដាលអំពីពលរដ្ឋសកម្ម (Active Citizenship)

យុវជន SKYE បានចូលរួមក្នុងការបណ្ដុះបណ្ដាល អំពី ពលរដ្ឋសកម្ម ដែលពួកគេបានទទួលបទពិសោធន៍ផ្ទាល់អំពី ការធ្វើផែនការ ការគ្រប់គ្រង និង ការអនុវត្ត។

ការបណ្ដុះបណ្ដាលនេះ បានផ្ដោតជាពិសេសលើការពង្រឹងភាពជាអ្នកដឹកនាំ និង ជំនាញសំរបសំរួល ដោយអោយពួកគេមានចំណេះដឹង និង ឧបករណ៍គ្រប់គ្រាន់ ក្នុងការដឹកនាំសកម្មភាពអភិវឌ្ឍសហគមន៍របស់គេ។

មេរៀនពលរដ្ឋសកម្ម នឹងជួយអោយយុវជនមានសមត្ថភាព និង អំណាច ក្នុងការដឹកនាំយុវជន និង សហគមន៍ ឲ្យក្លាយជាសហគមន៍ ដ៍ល្អផូរផង់របស់ពួកគេ។



## ការអភិវឌ្ឍន៍ និង កសិដ្ឋានបន្លែធន់នឹងអាកាសធាតុ

លោក រដ ហេន ជាកសិករម្នាក់ពីភូមិបដិវត្ត បានផ្លាស់ប្ដូរពីវិធីធ្វើកសិកម្មបែបបុរាណមកជាកសិកម្មបន្លែដែលអាចធន់នឹងការប្រែប្រួលអាកាសធាតុ។ បន្ទាប់ពីចូលរួមជាសមាជិក CIDG (ក្រុមគំនិតផ្ដួចផ្ដើម) តាមរយៈ PNKS លោកបានទទួលជំនាញបណ្ដុះបណ្ដាល ដូចជាបច្ចេកទេសដំណក់ទឹក (drip irrigation)។ ប្រព័ន្ធដំណក់ទឹកនេះ បានធ្វើឲ្យការថែទាំកាន់តែងាយស្រួល ប្រើទឹកតិច និងកាត់បន្ថយស្មៅដុះ ដោយធ្វើឲ្យបន្លែមានការលូតលាស់ល្អជាងមុន។

លោកហេនបានសង្កេតឃើញសហគមន៍មានការរីកចម្រើន មិនត្រឹមតែជីវិតគ្រួសាររបស់គាត់ទេ គឺសហគមន៍ទាំងមូលផងដែរ។ ភូមិរបស់គាត់បច្ចុប្បន្នមានធុងចំរោះទឹកស្អាត (WASH), បង្គន់អនាម័យ និង ហើយជារឿងៗ តែងឃើញប្រជាជនរួមគ្នាសម្អាតភូមិ ដែលជួយកែលម្អសុខភាពសហគមន៍។

លោកជឿជាក់ថា ការផ្លាស់ប្ដូរទាំងនេះមានសារៈសំខាន់ ក្នុងការកែលម្អជីវិតសមាជិកគ្រួសាររបស់គាត់ និង ក្រុមងាយរងគ្រោះផ្សេងទៀតផងដែរ។